## វប្បធម៌ដុងសឺន ( Dong Son culture)

នៅអំឡុងដើមពាក់កណ្តាលនៃសតវត្សទី២០ អ្នកស្រាវជ្រាវបានរកឃើញវត្ថុសិល្បៈជាច្រើនដែលធ្វើអំពីដីដុត និងអំពីលោហធាតុផ្សេងៗ ជាពិសេសឧបករណ៍សំរឹទ្ធ និងដែកជាច្រើន នៅក្នុងទីតាំងបញ្ចុះសពបុរាណមួយដែលស្ថិតនៅក្នុងភូមិឈ្មោះ ថាដុងសឺនក្នុងខេត្ត Thanh-hôa ក្នុងប្រទេសវៀតណាមៗ ទម្រង់នៃវត្ថុសិល្បៈដែលបានរកឃើញនោះ ជាពិសេសស្គរសំរឹទ្ធ ត្រូវបានអ្នកស្រាវជ្រាវហៅថាជា វប្បធម៌ដុងសឺនឬអរិយធម៌ដុងសឺន (រូបលេខ១-២)។

អ្នកស្រាវជ្រាវយល់ថា ការរកឃើញស្គរសំរិទ្ធនៅស្ថានីយ៍កប់សពដុងសឺន គឺជាការលេចឡើងនៅការប្រើប្រាស់ស្គរសំរឹទ្ធមុនគេក្នុងតំបន់អាស៊ីអាគ្នេយ៍។ ស្គរបែបនេះប្រហែលជាត្រូវបានប្រើប្រាស់ទាំងសម្រាប់សហគមន៍ពិធីបុណ្យ និងជាវត្ថុបញ្ចុះសពដែរ។ គួរបញ្ជាក់ថា ស្គរសំរឹទ្ធកើតឡើងដំបូងនៅក្នុងតំបន់ទន្លេក្រហម (ឥឡូវយូណាន ប្រទេសចិន និងវៀតណាមខាងជើង) នៅប្រមាណ៥០០ឆ្នាំ មុនគ.ស.ដែលស្ថិតនៅពុំឆ្ងាយពីគ្នានោះទេ។ ការលើកឡើងនេះ គឺដោយសារអ្នកស្រាវជ្រាវយល់ថា វប្បធម៌ដុងសឺនគឺទទួលឥទ្ធិពលពីអរិយធម៌ចិន (រាជវង្ស សួយ រហូតដល់ហាន)។[១]

តាមរយៈវត្ថុសិល្បៈ ជាពិសេសស្គរសំរឹទ្ធដែលបានរកឃើញនោះ បានបង្ហាញថា វប្បធម៌នេះ មានកាលបរិច្ឆេទស្ថិតក្នុងយុគសំរិទ្ធ រហូតដល់យុគដែក ហើយបរិបទនៃការបញ្ចុះសពនៅវប្បធម៌នេះ គឺស្រដៀងគ្នាទៅនឹងតំបន់នៃទន្លេ Ma និងCa ភាគខាងជើងវៀតណាមជាប់នឹងប្រទេសចិន។[២] លើសពីនេះ តាមទម្រង់បច្ចេកទេសនៃការផលិតវត្ថុអំពីលោហ អ្នកស្រាវជ្រាវលើកឡើងថា វត្ថុទាំងនោះ គឺមកពីប្រទេសចិន (រូបលេខ៣)។[៣]

ស្គរសំរឹទ្ធដែលរកឃើញក្នុងតំបន់នេះត្រូវបានហៅថា ស្គរ Dong Son ហើយ ក៏ឃើញមាននៅតាមបណ្តាស្ថានីយក្នុងតំបន់ស្ថានីយយុគសំរឹទ្ធ និងយុគដែក ក្នុងតំបន់អាស៊ីអាគ្នេយ៍ដីគោកផ្សេងទៀតដូចជានៅ ខ្មែរ ថៃ ជាដើម (រូបលេខ៤-៦ )។

---

[១] Higham 2014, p.200.

[២] Higham 2014, p.205.

[៣] https://www.academia.edu/34873699/Dong_Son_Culture_pdf

អត្ថបទដោយ៖ អេង តុលា

ប្រភេទនៃស្គរដុងសឺនត្រូវបានហៅថា Heger គឺជាការហៅតាមការបែងចែកប្រភេទស្គរសំរិទ្ធក្នុងតំបន់អាស៊ីអាគ្នេយ៍ដោយ លោក Franz Heger។ លោក Heger បានបែងចែកស្គរសំរិទ្ធក្នុងតំបន់អាស៊ីអាគ្នេយ៍ជា៤ប្រភេទផ្សេងគ្នា។

គួរឱ្យកត់សម្គាល់រូបរាង និងទម្រង់នៃស្គរនេះ គឺបង្ហាញអំពីជំនឿ និងមជ្ឈដ្ឋានរស់នៅនាសម័យបុរាណ។ នៅខាងលើនៃស្គរភាគច្រើន គឺឆ្លាក់រូបផ្កាយ និងខ្លះទៀតមានរូបជាសត្វ ដូចជាបក្សី ឬសត្វកង្កែបជាដើម ដែលទាក់ទងនឹងទឹក។ តាមរយៈការរូបភាពនៃសត្វទាំងនោះ អ្នកស្រាវជ្រាវយល់ថា ស្គរនេះត្រូវបានប្រើប្រាស់ក្នុងពិធីសុំទឹកភ្លៀង និងពេលមានមនុស្សស្លាប់ គេបានបញ្ចុះស្គរនេះជាមួយប្រហែលក្នុងន័យត្រជាក់ត្រជុំជាដើម។[៨]

យើងពុំបានដឹងអំពីអាយុចាស់ជាងគេនៃស្គរទាំងនេះទេ ប៉ុន្តែប្រហែលមានអាយុ ២៥០០ឆ្នាំ។ អ្វីដែលមិនប្រាកដនោះ គឺមុខងាររបស់ស្គរទាំងនោះ។ ទ្រឹស្ដីជាច្រើនត្រូវបានអ្នកស្រាវជ្រាវលើកជាពីរចំណុច ដែលចំណុចទីមួយស្គរនេះ គឺជាឧបករណ៍ភ្លេងក្នុងពិធីបុណ្យ និងចំណុចទីពីរ គឺវត្ថុពាណិជ្ជកម្មដែលឃើញនៅតំបន់ផ្សេងៗក្នុងអាស៊ីអាគ្នេយ៍។ មានអ្នកស្រាវជ្រាវជាច្រើនចោតជាសំណួរលើតួនាទីនៃស្គរសំរិទ្ធក្នុងវប្បធម៌ដុងសឺន និងនៅតំបន់ផ្សេងៗទៀត ដែលប្រហែលស្គរនេះដើរតួនាទីជាវត្ថុអំណោយ ដោយឧទាហរណ៍ស្គរនៅប្រទេសឥណ្ឌូណេស៊ីមិនត្រូវបានផលិតក្នុងស្រុកទេ ប៉ុន្តែគេដឹងថានាំមកពីឥណ្ឌូចិន។[៩]

សរុបមកវប្បធម៌ដុងសឺន គឺទទួលឥទ្ធិពលពីអរិយធម៌ចិន ទាំងបច្ចេកទេសនៃការផលិតលោហធាតុ និងរបៀបនៃការកប់សពជាដើម ហើយវត្ថុសំខាន់នៃវប្បធម៌នេះ គឺជាស្គរសំរិទ្ធដែលឃើញមាននៅប្រទេសកម្ពុជា ថៃ និងវៀតណាម ជាដើម៕

---

[៨] Tambours de bronze et circumambulations cérémonielles - Persée (persee.fr)

[៩] Ibid

អត្ថបទដោយ៖ អេង តុលា




រូបលេខ១ ៖ ផែនទីនៃវប្បធម៌ដុងសឺន ប្រភព៖ Nam C. Kim



រូបលេខ២៖ ដាវសំរឹទ្ធក្នុងវប្បធម៌ដុងសឺន ប្រភព៖ Wikipedia



រូបលេខ២៣ ៖ ផ្លែលំពែង    ប្រភព៖ Vnnews



រូបលេខ២៤៖ ស្គរសំរិទ្ធដុងសឺន   ប្រភព៖ Vnnews

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥៖ រូបផ្កាយនៅលើស្គរ  ប្រភព៖ vovworldvn



រូបលេខ២៦៖ ស្គរសំរិទ្ធដុងសឺន    ប្រភព៖ Wikipedia

អត្ថបទដោយ៖ អេង តុលា